

## ជំពូកទី ១១

# ការជួយកូនរបស់អ្នកឱ្យដឹងថានាងនៅកន្លែងណា

(ការរៀនរកទិសដៅសំរាប់ការដើរ)

**វ៉ានី** ជាកុមារីតូចម្នាក់ដែលពិការភ្នែក នាងកើតនៅភូមិមួយក្នុងប្រទេសឥណ្ឌា។ យាយរបស់**វ៉ានី**ឈ្មោះ**បាកា** ក៏ពិការភ្នែកដែរ ហើយមានសមត្ថភាពបង្ហាញ**ជីវ៉ាន**និង**អារុណា** ដែលជាឳពុកម្តាយរបស់**វ៉ានី**ពីវិធីទាំងឡាយដើម្បីបង្រៀន**វ៉ានី**។ ពេល**វ៉ានី**មានអាយុ 2 ឆ្នាំ នាងចេះស្ទាបរកផ្លូវដោយសសៀរតាមជញ្ជាំង និងគ្រឿងសង្ហារឹមដូចជា តុ, ទូ, កៅអី។ នាងដើរយឺតៗ នាងប្រើម្រាមដៃពិនិត្យរាវរកស្នាមបែក, កន្លែងរដិបរដុប, និងស្នាមប្រេះនីមួយៗយ៉ាងប្រយ័ត្នប្រយែង។ ឥឡូវនេះក្រុមគ្រួសាររបស់**វ៉ានី**ចង់បង្រៀននាងដើរក្នុងផ្ទះដោយមិនបាច់កាន់ ឬ តោងរបស់របរអ្វីឡើយ។



ថ្ងៃនេះ **បាកា**កំពុងពន្យល់ប្រាប់**ជីវ៉ាន**និង**អារុណា** ពីរបៀបដែលគាត់បំលាស់ទីពីកន្លែងមួយទៅកន្លែងមួយ។ "នៅពេលម៉ែចង់ដើរពីទ្វារមុខទៅកៅអីសំណប់ចិត្តរបស់ម៉ែ, ម៉ែដើរ 8 ជំហាន, គឺម៉ែដើរហួសតុបន្តិច បន្ទាប់មកម៉ែងាកបញ្ឆិតទៅឆ្វេងបន្តិច ហើយម៉ែដើរ 4 ជំហានទៀត។ ពេលនោះម៉ែយកដៃរាវរកកៅអីដើម្បីឱ្យដឹងពិតប្រាកដថា កៅអីនៅទីនោះ ពីព្រោះម៉ែនៅចាំពេលមួយនោះ នរណាម្នាក់បានរើយកកៅអីចេញ ហើយម៉ែអង្គុយលើខ្យល់!" **បាកា**សើចពេលគាត់នឹកឃើញរឿងនោះ។

រឿងរ៉ាវរបស់**បាកា**មិនគួរឱ្យអស់សំណើចទេ។ វាជាការសំខាន់សំរាប់ឱ្យយើងយល់ ថាតើវាពិបាកយ៉ាងណាសំរាប់កុមារពិការភ្នែកក្នុងការរៀនបំលាស់ទីជុំវិញ។ ដើម្បីឱ្យ**វ៉ានី**រៀនដើរដោយមិនកាន់ ឬ តោងរបស់របរអ្វីមួយ នាងត្រូវចងចាំយ៉ាងលំអិតថា ត្រូវដើរប៉ុន្មានជំហាន ហើយត្រូវបត់នៅចម្ងាយប៉ុន្មាន។ ក្រុមគ្រួសាររបស់**វ៉ានី**ត្រូវតែមានចិត្តអំណត់ពីព្រោះ**វ៉ានី**ត្រូវតែខិតខំអនុវត្តសកម្មភាពយ៉ាងច្រើនទៀត។

## វិធីដែលកុមាររៀនដើម្បីឱ្យដឹងថា នាងនៅកន្លែងណា

កុមារដែលអាចមើលឃើញប្រើភ្នែករបស់នាងដើម្បីឱ្យដឹងថានាងនៅកន្លែងណា និងវត្ថុនៅត្រង់ណា ។ កុមារដែលមិនអាចមើលឃើញច្បាស់ត្រូវការដឹងអំពីអ្វីៗទាំងនេះផងដែរ តែនាងត្រូវតែរៀនប្រើវិញ្ញាណដទៃទៀត ។ នៅពេលនាងចេះដឹងអំពីករណីទាំងនោះ នាងនឹងមានលទ្ធភាពបំលាស់ទីជុំវិញផ្ទះរបស់នាង ក្រោយមកទៀតនាងក្លាយជាក្មេងសកម្មនៅក្នុងសហគមន៍ ។ កុមារត្រូវរៀនអំពីការរកទិសដៅដើរដោយខ្លួនឯង :-




**នាងត្រូវតែដឹងពីកន្លែងដែលរាងកាយនាងមានទំនាក់ទំនងចំពោះវត្ថុ។**




**នាងត្រូវតែដឹងពីកន្លែងដែលវត្ថុមួយមានទំនាក់ទំនងចំពោះវត្ថុដទៃទៀត។**

អ្នកអាចជួយកូនរៀនបំណិនការរកទិសដៅដើរ :- (1) បង្រៀននាងអំពីរាងកាយរបស់នាង និងពីរបៀបដែលវាអាចធ្វើចលនា, (2) ការជួយឱ្យនាងអភិវឌ្ឍវិញ្ញាណដឹងទាំងឡាយដែលផ្តល់ព័ត៌មានសំខាន់អំពីអ្វីៗនៅជុំវិញខ្លួននាង និង (3) ការគិតអំពីអ្វីៗនៅជុំវិញផ្ទះអ្នក ឬ នៅក្នុងភូមិដែលអាចប្រើដើម្បីជាបង្គោលសំគាល់កំណត់ទិសដៅ ឬ ចំងាយផ្លូវ ។

## ការយល់ដឹងអំពីរាងកាយ

ក្មេងដឹងឈ្មោះនៃផ្នែករាងកាយរបស់នាងដោយការមើល និងធ្វើត្រាប់តាមអ្នកដទៃ ។ ក្មេងដែលមិនអាចមើលឃើញច្បាស់ដឹងផ្នែកផ្សេងៗនៃរាងកាយរបស់នាង នៅពេលអ្នកបង្រៀននាងឱ្យចេះប្រើវិញ្ញាណ ការស្តាប់ និងការស្ទាប ។ សំរាប់សកម្មភាពដែលជួយទារកតូចរៀនអំពីផ្នែករាងកាយរបស់នាង និងការអភិវឌ្ឍវិញ្ញាណទាំងឡាយ ចូរអានជំពូកទី 5 "សកម្មភាពសំរាប់ទារកតូច" ។ សកម្មភាពដ៏ច្រើនទាំងនេះ គឺល្អសំរាប់កុមារធំៗផងដែរ ។

### ➤ វិធីជួយកូនរៀនឱ្យស្គាល់ផ្នែកផ្សេងៗនៃរាងកាយរបស់នាង




ចូរប្រឌិតល្បែងកំសាន្តដែលអ្នកស្នើឱ្យកូនធ្វើអ្វីៗជាមួយផ្នែកផ្សេងៗនៃរាងកាយរបស់នាង និងជាមួយរាងកាយរបស់អ្នក ។ នេះជាឧទាហរណ៍មួយចំនួន ដើម្បីផ្តល់ជាគំនិតខ្លះៗសំរាប់អ្នក :-

ស្នើឱ្យកូនរបស់អ្នកស្ទាបផ្នែកណាមួយនៃរាងកាយរបស់នាង ហើយបន្ទាប់មកឱ្យនាងស្ទាបចំណែកដូចគ្នានោះលើរាងកាយរបស់អ្នក ។

ចូរស្នើឱ្យកូនរមៀលខ្លួនលើកម្រាលផ្ទះ និងហៅផ្នែកឈ្មោះនីមួយៗនៃរាងកាយនាង នៅពេលផ្នែកនោះប៉ះនឹងកម្រាលផ្ទះ ។ នេះជាល្បែងកំសាន្តមួយក្រុមល្អដែរ ។







ចូរយកកំណាត់រុំជុំវិញចំណែកខុសៗគ្នានៃរាងកាយរបស់ក្មេង និងស្នើឱ្យនាងស្រាយកំណាត់ចេញ ។ ចូរពន្យល់ប្រាប់ឈ្មោះនីមួយៗនៃផ្នែករាងកាយរបស់នាង និងមុខងាររបស់ផ្នែករាងកាយនោះ ។




ចូលើកទឹកចិត្តក្មេងឱ្យនាងចេះងក់ក្បាល, ទាត់, ធាក់, និងគ្រវីដៃ ហើយនិយាយផ្នែកឈ្មោះនៃរាងកាយដែលនាងប្រើ ។

**➤ វិធីជួយកូនរៀនអំពីការទាក់ទងរវាងរាងកាយរបស់នាង និងវត្ថុដទៃទៀត**

កូនអ្នកត្រូវការរៀនអំពីគំនិតដូចជា "នៅពីមុខអ្នក និងនៅខាងឆ្វេងអ្នក" ដើម្បីឱ្យដឹងថាវត្ថុនៅកន្លែងណា។ នេះជាវិធីមួយចំនួនដើម្បីជួយនាងរៀនសូត្រ។

ចូរសាកល្បងទាក់ទាញចំណាប់អារម្មណ៍នាងជាមួយនឹងប្រដាប់លេងមួយដែលបញ្ចេញសូរសម្លេង។ សូមប្រាប់នាងពីទីតាំងនៃប្រដាប់លេង តើវា**នៅពីមុខ** ឬ **ពីក្រោយ** ឬ **នៅខាងស្តាំ** ឬ **នៅខាងឆ្វេង**។ បន្ទាប់មកយកប្រដាប់លេងទៅដាក់កន្លែងផ្សេងទៀត ប្រាប់នាងពីទីតាំងរបស់វា ហើយចាំមើលបើនាងអាចរកប្រដាប់លេងឃើញដោយខ្លួនឯង។




**បើនាងមានបញ្ហាចំណាំខាងណាស្តាំ, ខាងណាឆ្វេង, ចូរចងខ្សែបូរ ឬ ខ្សែដៃត្រង់កដៃម្ខាងរបស់នាង។**




ក្រោយពេលនាងអាចប្រាប់ ឬ ស្គាល់ពីខាងស្តាំរាងកាយ ឬ ពីខាងឆ្វេងហើយ ចូរហុចវត្ថុខុសៗគ្នាឱ្យនាង ហើយប្រាប់ឱ្យនាងដាក់វត្ថុទាំងនោះទៅម្ខាង ឬ ទៅកន្លែងផ្សេងទៀត។ ចូរបង្កើតល្បែងលេងនោះឱ្យពិបាកបន្តិចម្តងៗ។




ចូរប្រឌិតល្បែងកំសាន្តដែលធ្វើឱ្យនាងចូល**ក្រោម**វត្ថុ (ដូចជា តុ ឬ គ្រែ) **នៅលើ**វត្ថុ (ដូចជាគ្រែ) **នៅចន្លោះ** ឬ **ជុំវិញ**វត្ថុ (ដូចជាតុនិងកៅអី) **ចូលតាម**វត្ថុ (ដូចជាទ្វារ) និង**ខាងក្នុង**វត្ថុ (ដូចជាប្រអប់)។ ចូរពន្យល់ប្រាប់ពីចលនានីមួយៗ។




ចូរប្រឌិតល្បែងកំសាន្តដែលនាងត្រូវតែធ្វើចលនារាងកាយដើរទៅមុខ ថយក្រោយ ឬ ទៅចំហៀងដើម្បីរកឱ្យឃើញប្រដាប់លេង។ ចូរពន្យល់នាងពីចលនានីមួយៗ។ បើអ្នកប្រឌិតបទចម្រៀងដែលរៀបរាប់ពីឈ្មោះនៃចលនានីមួយៗ នាងនឹងចងចាំចលនាទាំងនោះបានល្អប្រសើរ។

## **គំហើញ (ការមើលឃើញ)**

កុមារដែលអាចមើលឃើញខ្លះៗអាចប្រើគំហើញដើម្បីជួយឱ្យដឹងពីការរកទិសដៅដោយខ្លួនឯង ជាពិសេសបើអ្នកជួយដល់កូន ។

បើកូនអាចមើលឃើញពន្លឺ ចូរផ្តល់ទិសដៅដល់នាងដោយប្រើប្រភពពន្លឺជាចំណុចចាប់ផ្តើម ។







បើកូនអាចមើលឃើញពន្លឺ ចូរបើកភ្លើងបំភ្លឺទុកឱ្យនាង ដូច្នេះនាងអាចដើរតម្រង់ទិសរកអ្វីៗដែលនៅជុំវិញខ្លួននាងបាន នៅពេលនាងដើរចូលមកបន្ទប់ ។



ចូរដាក់ភ្លើងបំភ្លឺនៅកន្លែងដែលកំពស់ជណ្តើរប្រែប្រួល ( ទាប-ខ្ពស់) ឬ នៅជិតអ្វីមួយដែលកូនអ្នកត្រូវការចំណាំដើម្បីធ្វើការបំលាស់ទី (ដើរ) ដោយសុវត្ថិភាព ។




បើសិនជាកូនអាចមើលឃើញពណ៌ចែងចាំង ចូរដាក់កំណាត់ពណ៌ ឬ បិទស្កុតពណ៌, លាបថ្នាំពណ៌ ឬ វត្ថុដែលមានពណ៌ប្លែកៗពីគ្នានៅលើទ្វារ និងកន្លែងផ្សេងៗទៀតខាងក្រៅ ដើម្បីឱ្យនាងអាចចំណាំបាន ។ នៅពេលនាងឃើញពណ៌ទាំងនេះ នោះនាងនឹងដឹងថានាងនៅកន្លែងណា ។

## ការស្តាប់

ការស្តាប់មានសារៈសំខាន់ជាពិសេសចំពោះកុមារដែលមិនអាចមើលឃើញច្បាស់ ពីព្រោះវាផ្តល់ព័ត៌មានឱ្យនាងពីអ្វីៗដែលមិននៅក្បែរ ។ សម្លេងជួយកុមារពិការភ្នែកឱ្យដឹងថាវត្ថុនោះជាអ្វីមួយ, វានៅកន្លែងណា, និងវានៅចំងាយណា ។ ចូរនាំកូនមកឱ្យជិតល្មមដើម្បីឱ្យនាងប៉ះនឹងវត្ថុដែលកំពុងបញ្ចេញសម្លេងឱ្យញឹកញាប់តាមដែលអ្នកអាចធ្វើទៅបាន ។

### ➤ វិធីជួយកូនឱ្យចេះកំណត់សម្លេង និង ទីតាំងរបស់សម្លេង

ចូរលេងល្បែងកំសាន្តមួយ ដែលធ្វើឱ្យកូនអ្នកហៅឈ្មោះសម្លេងទាំងឡាយប្រចាំថ្ងៃនៅផ្ទះ និងនៅក្នុងសហគមន៍ - ដូចជា សម្លេងទ្វារកំពុងបិទ សម្លេងកៅអីកកិតផ្ទប់នឹងកម្រាលផ្ទះ ឬ សម្លេងម៉ាស៊ីនដេរ ។







ចូរលេងល្បែងទាយដែលធ្វើឱ្យកូនអ្នកអាចកំណត់ ឬ រកឃើញសមាជិកក្រុមគ្រួសារ និងសត្វនានាតាមរយៈសម្លេងដែលសត្វទាំងនោះតែងបញ្ចេញតាមធម្មតា ។




អ្នកក៏អាចប្រាប់ឱ្យកូនខិត ឬ ដើរឆ្ពោះទៅរកសម្លេង ។

ចូរឱ្យកូនអ្នកស្តាប់សម្លេងសម្រឹបជើងរបស់អ្នក នៅពេលអ្នកកំពុងដើរឆ្ពោះទៅរកនាង ហើយបន្ទាប់មកដើរចេញឆ្ងាយពីនាង ។ ចូរសង្កេតមើលបើនាងអាចដឹងថា តើអ្នកដើរទៅទិសខាងណា ឬ អ្នកត្រូវទះដៃពេលអ្នកដើរមកជិតនាង ហើយដើរចេញឆ្ងាយពីនាងវិញ ។ បន្ទាប់មកទៀតចូរឈប់ដើរ ហើយប្រាប់ឱ្យនាងរកអ្នក ។




ចូរបង្រៀនកូនអ្នកឱ្យស្តាប់សម្រឹបជើង (ឬ ឈើច្រត់) របស់នាង ថាតើវាមានសម្លេងយ៉ាងណាពេលដើរ ហើយប្រែប្រួលដូចម្តេចនៅពេលនាងនៅជិតផ្ទះ ឬ ជញ្ជាំង និងនៅទីវាល ។ ជាមួយការអនុវត្ត នាងអាចប្រាប់ថាអ្វីៗនៅជិតប៉ុណ្ណាតាមរយៈសម្លេងទាំងនេះ ។ បំណិនទាំងនេះនឹងជួយនាងនៅពេលនាងកំពុងដើរដោយខ្លួនឯងនៅក្នុងសហគមន៍ ។



## ការស្ទាប, ប៉ះ, និង អារម្មណ៍ (ដែលទទួលបានពីការស្ទាប/ប៉ះ)

ដើម្បីដឹងថានាងនៅកន្លែងណា កុមារត្រូវការរៀនចំណាំអំពីទ្រង់ទ្រាយ, ទម្ងន់, និងវត្ថុទាំងឡាយដែលមានសភាពខុសពីគ្នា (ឧទាហរណ៍ :- ទន់, រលោង, ក្រាស់, ស្តើង, គ្រើម ឬ ស្អៀប) នៅជុំវិញនាង ។ នាងក៏ត្រូវយកចិត្តទុកដាក់លើបរិវេណដីដែលប៉ះនៅក្រោមបាតជើង និងរបៀបដែលសីតុណ្ហភាពប្រែប្រួលពេលនាងដើរពីកន្លែងមួយទៅកន្លែងមួយទៀត ។

### ➤ វិធីជួយកូនអភិវឌ្ឍវិញ្ញាណនៃការស្ទាប/ប៉ះរបស់នាង

នៅពេលថ្ងៃ ចូរលើកទឹកចិត្តកូនអ្នកឱ្យប៉ះវត្ថុទាំងឡាយដែលមានទំហំ, ទម្ងន់, និងសភាពខុសៗគ្នា ។ ចូរប្រាប់នាងឱ្យរៀបរាប់ប្រាប់អ្នកពីរបស់អ្វីដែលនាងបានប៉ះ ។ បន្ទាប់មកអ្នកអាចដាក់វត្ថុខុសៗគ្នា និងដែលមានសភាពខុសគ្នានៅជុំវិញផ្ទះដើម្បីជួយកូនអ្នកឱ្យដឹងថានាងនៅកន្លែងណា ។




ចូរលើកទឹកចិត្តកូនអ្នកឱ្យដើរជើងទទេនៅលើបរិវេណដីខុសប្លែកពីគ្នា ឧទាហរណ៍ ដើរនៅលើដី, ស្មៅ, និង គ្រួស ធ្វើដូច្នេះនាងអាចដឹងថា ប្រភេទវត្ថុនីមួយៗបែបណា ។ បើនាងមានស្បែកជើងពាក់ ចូរឱ្យនាងពាក់វា ហើយសម្គាល់បរិវេណដីថាតើវាខុសប្លែកគ្នាយ៉ាងណាពេលនាងដើរ ។ ព័ត៌មានប្រភេទនេះនឹងជួយនាងឱ្យដឹងថានាងនៅកន្លែងណា ពេលនាងកំពុងដើរនៅខាងក្រៅ ឬក៏ជួយនាងឱ្យរក្សាការដើរនៅលើផ្លូវ (ដើរមិនខុសផ្លូវ) ។





ចូរបង្រៀនកូនអ្នកពីវិធីប្រើបាតជើង ដើម្បីស្ទាបអ្វីដែលមានកំពស់ខុសៗគ្នា ដូចជា ចិញ្ចើមថ្នល់ ឬ ផ្លូវដើរ។

ចូរលើកទឹកចិត្តនាងឱ្យចេះចំណាំពេលសីតុណ្ហភាពប្រែប្រួល ពេលនាងកំពុងដើរពីកន្លែងមួយទៅកន្លែងមួយទៀត។

**នៅពេល អាលីន ទទួលអារម្មណ៍ ខ្យល់បក់រំភើយៗ នាងដឹងថានាងដើរ ជិតដល់មាត់ទ្វារផ្ទះរបស់នាងហើយ។**





**សោភ័ណ ដឹងថានាងទទួលអារម្មណ៍ពីកំដៅ ព្រះអាទិត្យលើខ្លួននាង ពេលនាងដើរពីផ្សារ ត្រឡប់ទៅផ្ទះវិញនៅពេលរសៀល។**

## ការហិតក្លិន

ក្លិនក៏ដូចជាសម្លេងដែរ អាចផ្តល់ព័ត៌មានអំពីអ្វីៗទាំងឡាយដែលនៅក្បែរ ឬ នៅចម្ងាយសមល្មមមួយ ។ ដើម្បីស្វែងយល់ការប្រើក្លិនយ៉ាងណានោះ កូនរបស់អ្នកត្រូវការរៀនកំណត់ឱ្យស្គាល់ក្លិនប្លែកៗពីគ្នា និងកន្លែងដែលក្លិនទាំងនោះជះចេញមក ។ អ្នកអាចប្រើកិច្ចការប្រចាំថ្ងៃរបស់អ្នក ដើម្បីជួយកូនរៀនអំពីក្លិននានានៅក្នុងសហគមន៍ ។

### ➤ វិធីជួយធ្វើឱ្យវិញ្ញាណនៃការហិតក្លិនរបស់កូនបានប្រសើរឡើង

នៅពេលអ្នកកំពុងដើរជាមួយកូន ចូរពន្យល់ប្រាប់កូនអំពីក្លិនប្លែកៗគ្នានៅជុំវិញ ឧទាហរណ៍ ក្លិនម្ហូបអាហារ, ផ្កា, សត្វ, កាកសំណល់, និងសំរាម ។ បើអាចធ្វើបានគ្រប់យ៉ាង ចូរនាំកូនទៅឱ្យជិតល្មមដើម្បីប៉ះវត្ថុដែលនាងធុំក្លិន ។




**លើកក្រោយនៅពេលអ្នកនិងកូនដើរជាមួយគ្នា ចូរសង្កេតមើលបើនាងអាចប្រាប់ឈ្មោះក្លិនទាំងឡាយដោយខ្លួននាង...**




**...ហើយប្រាប់ឱ្យនាងដើរឆ្ពោះទៅក្លិននោះ ឬ ដើរចេញឱ្យឆ្ងាយពីក្លិននោះ។**




នៅពេលថ្ងៃ ចូរចង្អុលប្រាប់ពីម្ហូបអាហារប្លែកៗពីគ្នា និងវត្ថុ ឬ សម្ភារៈទាំងឡាយនៅក្នុងផ្ទះដែលមានក្លិនឆួលខ្លាំង ។ ចូរសង្កេតមើលបើសិនជាកូនអ្នកអាចកំណត់ ឬ សម្គាល់បាន ។

## បំណិនយល់ដឹងអំពីការរៀនរកទិសដៅផ្សេងទៀត

ដើម្បីក្លាយជាក្មេងមានម្ចាស់ការ កុមារត្រូវការដើរទៅកន្លែងថ្មីៗ និងធ្វើតាមការតម្រង់ទិស ។ សកម្មភាពទាំងនេះប្រហែលជាពិបាកសំរាប់កូនរៀន និងអាចធ្វើឱ្យកុមារភ័យខ្លាចនៅលើកដំបូង ។ វាក៏អាចពិបាកផងដែរចំពោះអ្នក ដើម្បីផ្តល់ការតម្រង់ទិសដែលនាងអាចធ្វើតាម ។ អ្នកអាចជាគ្រូបង្រៀនកាន់តែល្អប្រសើរសំរាប់កូន បើសិនជាអ្នក :-

- មុនដំបូង ចូរសាកល្បងសកម្មភាពទាំងនេះជាមួយបុគ្គលពេញវ័យណាម្នាក់ ។ ចូរយកកំណាត់ចងមុខឱ្យគ្នាទៅវិញទៅមក ហើយអនុវត្តឱ្យគ្រប់ជំហាន ។ ចូរពិភាក្សាគ្នាអំពីមេរៀនឱ្យច្បាស់លាស់ ( របៀបដែលអាចណែនាំកូនបានកាន់តែច្បាស់ ) ។
- បន្ទាប់មកសាកល្បងបង្រៀនកុមារដែលមើលឃើញម្នាក់ ។ ចូរយកកំណាត់ចងមុខកុមារ ហើយណែនាំនាងតាមជំហានដូចគ្នាដែលអ្នកបានសាកល្បងជាមួយបុគ្គលពេញវ័យ ។ ចូរសង្កេតមើលប្រតិកម្មរបស់នាងឱ្យបានល្អិតល្អន់ធ្វើដូច្នេះអ្នកអាចរកវិធីធ្វើឱ្យនាងទុកចិត្តឡើងវិញ និងលើកទឹកចិត្តនាង ។

### ➤ វិធីជួយកូនឱ្យធ្វើតាមទិសដៅ

នៅពេលកូនរបស់អ្នកដើរដោយខ្លួនឯងបានស្រួលបួលហើយ ចូរបង្រៀននាងពីរបៀបបែរ ឬ បត់ទៅខាងនេះ ឬ ខាងនោះ ។



**ជាមួយខ្នងនាងជាប់នឹងជញ្ជាំង ចូរប្រាប់ឱ្យនាងបែរទៅម្ខាងទាល់តែ...**



**...ស្មាម្ខាងនាងប៉ះនឹងជញ្ជាំង (បែរ 1/4) ឬ មួយចំណែក)...**

**...នាងកំពុងបែរមុខរកជញ្ជាំង (បែរកន្លះរង្វង់)...**



**...នាងកំពុងបែរចំហៀងចេញពីជញ្ជាំងដែលស្មាម្ខាងទៀតផ្ទុយទៅជញ្ជាំង (បែរ 3/4 ឬ បែរស្ទើរតែពេញរង្វង់) ហើយ...**



**...នាងកំពុងបែរទៅខាងមុខម្តងទៀត គឺបែរមួយជុំរង្វង់)**



ចូរលើកទឹកចិត្តនាងឱ្យយកចិត្តទុកដាក់ពីរបៀបដែលនាងបង្វិលប្រអប់ជើង ពេលនាងកំពុងអនុវត្តទិសដៅនេះ ។ នាងអាចដើរចេញឆ្ងាយពីជញ្ជាំងបន្តិចម្តងៗ ហើយអនុវត្តដោយខ្លួនឯង ។ ចូរចាំថា ត្រូវមានចិត្តអំណត់ ។ កូនអ្នកត្រូវការអនុវត្តជាច្រើនលើកច្រើនសារ មុនពេលនាងមានលទ្ធភាពប្តូរទិសដៅដោយខ្លួនឯង ។

## ➤ វិធីជួយកូនរៀនដើរនៅកន្លែងថ្មីមួយ

សកម្មភាពទាំងនេះនឹងជួយកូនរបស់អ្នករៀនអំពី :-

- កន្លែងសំគាល់ (វត្ថុ, សម្លេង ឬ ក្លិនអ្វីក៏ដោយដែលតែងតែស្ថិតនៅកន្លែងដដែលជានិច្ច) ។
- តម្រុយ (វត្ថុ, សម្លេង ឬ ក្លិនទាំងឡាយដែលផ្ដល់ដំណឹងល្អ តែវាមិនស្ថិតនៅកន្លែងដដែល) ។

សកម្មភាពទាំងនេះគួរតែធ្វើទៅតាមលំដាប់ដែលបានបង្ហាញនៅទីនេះ :-




1. ដំបូងចូរលេងល្បែងកំសាន្តមួយ នៅបរិវេណដែលកូនអ្នកស្គាល់ច្បាស់ ។ ចូរប្រាប់នាងថា អ្នកបានដាក់អ្វីមួយនៅលើគន្លងផ្លូវដែលនាងកំពុងដើរ ហើយសង្កេតមើលបើនាងអាចដើរចៀសវាដោយមិនរអិល ឬ ដួល ។ ប្រការនេះនឹងជួយនាងឱ្យកាន់តែមានអារម្មណ៍ជឿជាក់អំពីការព្យាយាមដើរនៅកន្លែងថ្មីៗ ។

2. បន្ទាប់មកអនុញ្ញាតឱ្យនាងកាន់ម្រាមដៃមួយរបស់អ្នក ហើយដើរមួយជំហានពីក្រោយអ្នកនៅលើកន្លែងថ្មីមួយ ។






3. ពេលអ្នកដើរ ចូរជួយនាងឱ្យចេះចំណាំកន្លែងសម្គាល់ និងតម្រុយ ។ អ្នកត្រូវបង្រៀននាងឱ្យច្បាស់លាស់អំពីកន្លែងសម្គាល់ដែលអាចបង្កគ្រោះថ្នាក់ដូចជា ទន្លេ, បឹងបួរ ឬ ផ្លូវថ្នល់ ។




4. នៅពេលនាងមានអារម្មណ៍ស្រួលចិត្តនៅកន្លែងនោះហើយ ចូរដើរតាមកន្លែងនោះម្តងទៀត តែលើកនេះអ្នកដើរថយក្រោយ នៅពីមុខនាង ហើយនិយាយទៅរកនាងខណៈដែលអ្នកកំពុងដើរ ។

5. នៅទីបញ្ចប់ ចូរដើរពីក្រោយនាងនៅខណៈដែលនាងរៀបរាប់ពីអ្វីៗនៅជុំវិញនាង ។

**ចូរអត់ធ្មត់ ដើម្បីឱ្យក្មេងមានចិត្តជឿជាក់ក្នុងការដើរម្នាក់ឯងនៅកន្លែងថ្មីៗ គឺត្រូវប្រើពេលច្រើនណាស់។**




6. នៅពេលកូនអ្នកមានទំនុកចិត្តហើយ ចូរផ្តល់ទិសដៅឱ្យនាងចាប់ផ្តើមត្រង់កន្លែងសម្គាល់ដែលនាងស្គាល់បានហើយ និងពន្យល់នាងថា នាងត្រូវដើរពីកន្លែងសម្គាល់នេះ ទៅកន្លែងណាមួយ ។ មុនដំបូងអនុវត្តក្នុងចម្ងាយខ្លីមួយ បន្ទាប់មកចូរបង្កើនចម្ងាយផ្លូវឱ្យឆ្ងាយបន្តិចម្តងៗ ។



## របៀបដែលសហគមន៍អាចជួយជ្រោមជ្រែង

មនុស្សម្នានៅក្នុងសហគមន៍អាចជួយបង្កឱ្យកាន់តែងាយស្រួលឡើង សំរាប់កូនអ្នកក្នុងការស្វែងរកផ្លូវរបស់នាង។ សមាជិកសហគមន៍អាចរៀនផងដែរ ដើម្បីផ្តល់ទិសដៅដែលជួយដល់នាងឱ្យចេះរកឃើញអ្វីៗដោយខ្លួននាងផ្ទាល់។ ជំពូកទី 13 និយាយអំពីតម្រូវការជួយពិសេសដែលសមាជិកសហគមន៍អាចផ្តល់ឱ្យកុមារដែលមិនអាចមើលឃើញច្បាស់។

មនុស្សម្នាក៏អាចដាក់កន្លែងសម្គាល់នៅកន្លែងផ្សេងៗដែលជួយឱ្យកូនរបស់អ្នករកផ្លូវឃើញ ឬ ដឹងថាត្រូវបត់នៅត្រង់ណា។ ភូមិផងរបងជាមួយ ឬ នៅក្នុងភូមិនីមួយៗតែងមានការខុសប្លែកពីគ្នា ដូច្នេះអ្នកនិងសហគមន៍របស់អ្នកត្រូវសំរេចចិត្តធ្វើអ្វីៗដែលត្រឹមត្រូវសំរាប់កូនរបស់អ្នក។ នេះគឺជាឧទាហរណ៍ពីរនៃការកំណត់ដាក់កន្លែងសម្គាល់ ដែលអាចជាគម្រោងរបស់សហគមន៍ដើម្បីជួយកុមារដែលមិនអាចមើលឃើញច្បាស់ :-



ដាក់បង្គោល ឬ ធ្វើអ្វីផ្សេងទៀត
នៅត្រង់ផ្លូវខ្វែង ដែលអាចជួយ
កូនអ្នករកផ្លូវរបស់នាង។



ចងដាក់ខ្សែពួរនាំផ្លូវ
ឬ បង្កាន់ដៃអាចជួយកូន
អ្នករកផ្លូវរបស់នាង។